**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.គ លេខ ១០.០១២/០៩ គជប.អគ្គ.ពស**

ភ្នំពេញ ថ្ងៃទី 7 ខែតុលា ឆ្នាំ២០០៩

# ទឹកជំនន់បន្តជន់លិចឃុំចំនួន ៣២ នៅខេត្តកំពង់ចាម និងក្រចេះ

តាមរបាយការណ៍របស់លេខាធិការដ្ឋានខេត្តរៀបចំការបោះឆ្នោត(លធ/ខប) បានឱ្យដឹងថា ទឹកជំនន់បានជន់លិចឃុំចំនួន ៣២ នៅខេត្តកំពង់ចាម និងខេត្តក្រចេះ បណ្តាលឱ្យមានការផ្លាស់ប្តូរទីតាំងនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅតាមបណ្តាឃុំទាំងនោះ ។

លោក សុខ ឈិន អនុប្រធាន លធ/ខប ខេត្តកំពង់ចាម បានមានប្រសាសន៍ថា ឃុំចំនួន ១៥ បានរងនូវការជន់លិចដោយទឹកជំនន់ហើយបណ្តាលឱ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅឃុំទាំងនោះមិនបានដំណើរការតាមប្រតិទិនកំណត់ ។ លោកបានបញ្ជាក់ទៀតថា ប៉ុន្តែថ្ងៃនេះ ឃុំទាំង១៥ បានដំណើរចុះឈ្មោះបោះឆ្នោតជាប្រក្រតី ពីព្រោះក្រុមប្រឹក្សា ឃុំ និងស្មៀនបានផ្លាស់ប្តូរទីតាំងចុះឈ្មោះទៅរកទីទួលខ្ពស់ និងចុះឈ្មោះបោះឆ្នោតលើទូក ។ ឃុំដែលរងនូវទឹកជំនន់ស្ថិតនៅក្នុងស្រុកចំនួន៥ គឺ ស្រុកក្រូចឆ្មារ មានឃុំចំនួន៣ ស្រុកកំពង់សៀមមានឃុំចំនួន៤ ស្រុកត្បូងឃ្មុំមានឃុំចំនួន៤ ស្រុកស្រីសន្ធរ មានឃុំចំនួន១ និងស្រុកស្ទឹងត្រង់មានឃុំចំនួន៣ ។

ចំពោះខេត្តក្រចេះមានឃុំចំនួន១៧ បានរងនូវការជន់លិចដោយទឹកជំនន់នេះផងដែរ ។ លោក អ៊ុង ស៊ីយឿន ប្រធាន លធ/ខប ខេត្តបានមានប្រសាសន៍ថា ឃុំដែលរងនូវទឹកជំនន់ស្ថិតនៅក្នុងស្រុកព្រែកប្រសព្វចំនួន៦ឃុំ ស្រុកឆ្លូងចំនួន៤ឃុំ ស្រុកឈ្នួលចំនួន១ឃុំ ក្រចេះចំនួន៣ឃុំ និងស្រុកសំបូរចំនួន៣ឃុំ ។ លោកបានបញ្ជាក់ទៀតថា ទោះបីឃុំទាំងនោះរងនូវផលប៉ះពាល់ដោយទឹកជំនន់ក៏ដោយ ក៏ដំណើរការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅជាធម្មតាពីព្រោះក្រុមប្រឹក្សាឃុំ បានផ្លាស់ប្តូរទីតាំងចុះឈ្មោះបោះឆ្នោតទៅរកទីទួលខ្ពស់ ។

តាមសេចក្តីរាយការណ៍ដាច់ដោយឡែកមួយទៀត គិតត្រឹមរសៀលថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ បានឱ្យដឹងថា ខេត្តកំពង់ធំ ចាប់តាំងពីថ្ងៃទី៣ ដល់ថ្ងៃទី៦ ខែតុលានេះ ទឹកជំនន់បានបង្កើនសកម្មភាពកាន់តែខ្លាំងឡើងៗជាលំដាប់បណ្តាលឱ្យភូមិ ឃុំ/សង្កាត់ ទាំងឡាយ ដែលនៅខាងលើផ្លូវជាតិលេខ៦ ត្រូវលិចលង់អស់ជាច្រើន ហើយធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការចុះឈ្មោះបោះឆ្នោតនៅតាមបណ្តាឃុំ/សង្កាត់ទាំងនោះ ។

នៅចុងឆ្នាំ២០០៩នេះ ខេត្តមួយចំនួននៃប្រទេសកម្ពុជាបាននឹងកំពុងរងនូវឥទ្ធិពល ខ្យល់ព្យុះកំបុតត្បូងកេតសាណា ដែលបណ្តាលឱ្យផលស្រូវ ដំណាំ សត្វពាហនៈ និងផ្ទះសំបែងប្រជាពលខូចខាត និងបាត់បង់ អស់មួយចំនួន ។ ហើយថ្មីៗនេះ កាកបាទក្រហមកម្ពុជា បានអំពាវនាវដល់សប្បុរសជនជួយផ្តល់នូវសំភារៈ ស្បៀងអាហារ ថវិកា ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ និងខ្យល់ព្យុះកំបុតត្បូង ។ ជាមួយគ្នានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានឧបត្ថម្ភថវិកាចំនួន ២ លានរៀលដល់កាកបាទក្រហមកម្ពុជាក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋរងគ្រោះ ។/

ព័ត៌មានបន្ថែម សូមទំនាក់ទំនងផ្នែកព័ត៌មាន ទូរស័ព្ទលេខ៖ 023 214 231 / 012 855 018 & Fax 023 214 374